**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**
លេខ:.....០៩៤ ប្រក.....ប.ស្ថ

# ប្រកាស
## ស្តីពី
## ការទទួលស្គាល់សហគមន៍តំបន់ការពារធម្មជាតិ "ភ្នំជ្រាប់ត្រីក្សាន្ត" នៃដែនជម្រកសត្វព្រៃ -ព្រៃឡង់- ស្ថិតនៅ ភូមិប្រាច់ ភូមិចំរើន និងភូមិផ្ដោច ឃុំប្រាច់ ស្រុកជ័យសែន ខេត្តព្រះវិហារ

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការគ្រប់គ្រងតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបង្កើតដែនជម្រកសត្វព្រៃ -ព្រៃឡង់-
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងបរិស្ថាន

## សម្រេច

**ប្រការ១._**

ត្រូវបានទទួលស្គាល់សហគមន៍តំបន់ការពារធម្មជាតិ **-ភ្នំជ្រាប់ត្រីក្សាន្ត-** នៃដែនជម្រកសត្វព្រៃ -ព្រៃឡង់- ស្ថិតនៅ ភូមិប្រាច់ ភូមិចំរើន និងភូមិផ្ដោច ឃុំប្រាច់ ស្រុកជ័យសែន ខេត្តព្រះវិហារ។



អគារមរតកតេជោ ជីឡូលេខ៥០៣ ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ: ០២៣ ២១៥ ០០៨/ ០២៣ ២១៥ ០០៦

**ប្រការ២.**_

សហគមន៍តំបន់ការពារធម្មជាតិ **«ភ្នំជ្រាប់ត្រីក្សាន្ត»** នៃដែនជម្រកសត្វព្រៃ «ព្រៃឡង់» មានផ្ទៃដីសរុប ទំហំ **១,៣៨៤.៧៩ ហិកតា** (មួយពាន់បីរយសែសិបប្រាំបីកន្លក់សញ្ញាចិតសិបប្រាំបួនហិកតា) ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធ កំណត់ដោយចំណុចគោល ដែលមាននិយាមកា (Datum: WGS1984) ដូចក្នុងតារាងខាងក្រោម៖

| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| A | 542912 | 1512234 | J | 542583 | 1509495 |
| B | 544128 | 1511519 | K | 542190 | 1509279 |
| C | 544864 | 1511212 | L | 541593 | 1508796 |
| D | 546362 | 1510996 | M | 540533 | 1508504 |
| E | 546457 | 1510511 | N | 539855 | 1509460 |
| F | 545784 | 1510269 | O | 539825 | 1510133 |
| G | 545377 | 1510219 | P | 539975 | 1510567 |
| H | 544730 | 1509952 | Q | 542115 | 1512482 |
| I | 543803 | 1509850 | | | |

| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| 1 | 547749 | 1509064 | 4 | 547698 | 1508465 |
| 2 | 548204 | 1508490 | 5 | 548290 | 1508665 |
| 3 | 547504 | 1508743 | | | |

**ប្រការ៣.**_

ការរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ **«ភ្នំជ្រាប់ត្រីក្សាន្ត»** ក្នុងគោលបំណងបង្កើនការចូលរួមគ្រប់គ្រងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងរួមចំណែកលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋានស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

**ប្រការ៤.**_

សហគមន៍តំបន់ការពារធម្មជាតិ **«ភ្នំជ្រាប់ត្រីក្សាន្ត»** នៃដែនជម្រកសត្វព្រៃ «ព្រៃឡង់» ត្រូវចុះកិច្ចព្រមព្រៀងជាមួយអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន នៃក្រសួងបរិស្ថាន។ សហគមន៍តំបន់ការពារធម្មជាតិ **«ភ្នំជ្រាប់ត្រីក្សាន្ត»** ត្រូវរៀបចំលក្ខន្តិកៈ និងផែនការគ្រប់គ្រងស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

**ប្រការ៥.**_

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦.**_

នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព គ្រប់អគ្គនាយក នៃអគ្គនាយកដ្ឋានចំណុះក្រសួង អគ្គាធិការ នៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរបរិស្ថានខេត្តព្រះវិហារ និងប្រធានសហគមន៍តំបន់ការពារធម្មជាតិ **«ភ្នំជ្រាប់ត្រីស្វាន្ត»** ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៤រោច ខែ មាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

កន្លែងទទួល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តព្រះវិហារ
- ដូចប្រការ៦ «ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ផែនទី ព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិព្រៃស្រអាងត្រីក្រាន្ត ក្នុងដែនជម្រកសត្វព្រៃ " ព្រៃឡង់ " ភូមិសាស្ត្រភូមិស្រអាង ភូមិប៉ពីល និងភូមិខ្វៀន ឃុំស្រអាង ស្រុកជ័យសែន ខេត្តព្រះវិហារ ផ្ទៃដី១៣៤៨.៧៩ហិកតា

យោងលិខិត : ប្រកាសលេខ ០៩៤ ចុះថ្ងៃទី០៥ ខែ មីនា ឆ្នាំ២០១៩ របស់ក្រសួងបរិស្ថាន




តារាងកូអរដោនេព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិ

| ID | X | Y |
|---|---|---|
| A | 542912 | 1512234 |
| B | 544128 | 1511519 |
| C | 544864 | 1511212 |
| D | 546382 | 1510996 |
| E | 546457 | 1510511 |
| F | 545784 | 1510269 |
| G | 545377 | 1510219 |
| H | 544730 | 1509952 |
| I | 543803 | 1509850 |
| J | 542583 | 1509491 |
| K | 542190 | 1509279 |
| L | 541593 | 1508796 |
| M | 540533 | 1508504 |
| N | 539855 | 1509460 |
| O | 539825 | 1510133 |
| P | 539975 | 1510567 |
| Q | 542115 | 1512482 |

| ID | X | Y |
|---|---|---|
| 1 | 547749 | 1509064 |
| 2 | 548204 | 1508490 |
| 3 | 547504 | 1508743 |
| 4 | 547688 | 1508465 |
| 5 | 548290 | 1508655 |

សញ្ញាសម្គាល់

មាត្រដ្ឋាន ១:៤០ ០០០

Map Coordinate System: UTM, Zone 48, Datum: WGS 1984